ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈសង្ឃនាយក
នៃព្រះរាជាណាចក្រកម្ពុជា

លេខៈ ១៩០/២០ ស.ន.ក.ជ

## ប្រគេន

## ព្រះមេគណ រាជធានី-ខេត្ត

**កម្មវត្ថុ ៖** ស្តីពីការបញ្ឈប់ការរំលាយបំណែក ឬបុរាណវត្ថុពេញលេញអំពីលោហធាតុ ដើម្បីសិតព្រះពុទ្ធបដិមា ឬរូបចម្លាក់ផ្សេងៗនៅតាមវត្តអារាម។

**យោង ៖** លិខិតលេខ ៣៣៣ ស.ណ ចុះថ្ងៃពុធ ១រោច ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី៥ ខែសីហា ឆ្នាំ២០២០ របស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ គណៈសង្ឃនាយក សូមប្រគេនព្រះមេគណរាជធានី-ខេត្ត ជ្រាបថា ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ បានខិតខំខ្នះខ្នែងក្នុងការការពារបុរាណវត្ថុ ប្រាសាទសំណង់ប្រវត្តិសាស្ត្រ ស្ថានីយ៍បុរាណនានា ដើម្បីជាប្រយោជន៍សម្រាប់កូនចៅជំនាន់ក្រោយបានស្គាល់ និងបានសិក្សារៀនសូត្រអំពីស្នាដៃរបស់បុព្វបុរសខ្មែរយើង។ ដើម្បីចូលរួមទប់ស្កាត់ការបំផ្លិចបំផ្លាញបុរាណដ្ឋាន និងការជួញដូរវត្ថុបុរាណផ្សេងៗ គណៈសង្ឃនាយក ស្នើដល់ព្រះមេគណ ព្រះអនុគណ និងព្រះចៅអធិការគ្រប់វត្ត ព្រះមេត្តាបញ្ឈប់ការបន្តប្រពៃណីសិតព្រះពុទ្ធបដិមា ឬសម្លាក់ផ្សេងៗដោយប្រើប្រាស់បំណែក ឬបុរាណវត្ថុពេញលេញអំពីលោហធាតុរួមមាន សំរិទ្ធ ប្រាក់ និងមាស លាយជាមួយស្ពាន់ ទង់ដែងថ្មី ឬបំណែកបុរាណវត្ថុផ្សេងៗទៀត នៅតាមវត្តអារាម។

អាស្រ័យដូចបានប្រគេនខាងលើ សូម ព្រះមេគណ មេត្តាសហការ និងប្រគេនដំណឹងនេះទៅតាមបណ្តាគ្រប់សាលាអនុគណ ដើម្បីអនុវត្តតាមសេចក្តីខាងលើឱ្យមានប្រសិទ្ធភាព និងការទទួលខុសត្រូវខ្ពស់។

សូម ព្រះមេគណ ទទួលនូវការស្រឡាញ់រាប់អានពីខ្ញុំព្រះករុណា។

ថ្ងៃព្រហស្បតិ៍ ៩រោច ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែសីហា ឆ្នាំ២០២០

**សម្តេចព្រះសង្ឃនាយក**

គណៈសង្ឃនាយក

នន្ទ_ង៉ែត

**ចម្លងជូនៈ**
- ក្រសួងធម្មការ និងសាសនា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- រដ្ឋបាលរាជធានី-ខេត្ត
-  "ដើម្បីជូនជ្រាប"
- ឯកសារ-កាលប្បវត្តិ